# មាតិការឿង

សេចក្តីផ្តើម

១. សច្ចភាព

២. ការពិចារណា

៣. ថាមពល

សរសេរដោយ ឧប សៅ សង្ហា

ថ្ងៃទី ៣ មករា ឆ្នាំ ២០១៥



**សួស្តី ឆ្នាំសាកល ថ្មី ២០១៥**

# សច្ចះភាព

La foi

អត្ថបទខាងក្រោមនេះ យើងដកស្រង់ ពីរឿងនិទាន «ប្រស្នា នៃ ព្រះចៅ **មីលិនដា** ចំពោះ ភិក្ខុ **បញ្ញា**»[1] ជាភាសាបារាំង យកមក សម្រួល ជា ភាសាខ្មែរ ហើយ ដោះជាដំបូន្មាន សំរាប់ជនជាតិខ្មែរសំរាប់ រកចម្លើយ នៅចំពោះមុខ មហន្តរាយជាតិ នា បច្ចុប្បន្ន។

## អ្វីជា ចរិតលក្ខណៈ នៃ សច្ចះភាព[2] ?

ជា **សម្រិតចិត្ត**[3] និង **សន្ទុះចិត្ត**។

**ហេតុអ្វីបានជា សច្ចះភាព មាន សម្រិតចិត្ត ជា ចរិតលក្ខណៈ ?**

ព្រោះ សច្ចះភាព អាចរំលាយ ឧបសគ្គ រំដោះគតិ ពីឧបសគ្គ ឲ មានចិត្តថ្លាឆ្វង់ និង បរិសុទ្ធ។

ឧបមា ស្តេចមួយអង្គ ដឹកនាំកងទ័ព មាន ដំរី សេះ សមិតរទេះ[4] ដើរឆ្លង ស្ទឹងតូចមួយ នាំឲទឹកស្ទឹងនោះល្អក់ បង្កើតជាភក់ ហើយក្រោយពីបាន ឆ្លងស្ទឹងរួច ព្រះរាជា បញ្ជាឲសេនា ដងទឹកស្ទឹងនោះ មកថ្វាយព្រះអង្គសោយ។ បើសិន ជាពួកសេនា មាន ថ្មពិសេស សំរាប់តម្រងទឹកភក់ឲក្លាយជាទឹកថ្លា បរិសុទ្ធ វិញថ្លាមៗ ហើយយកមកថ្វាយ ព្រះរាជាខ្លួន ដោយក្រាបទូលថា សូមមហារាជ្យ សោយទឹក ដ៏បរិសុទ្ធនេះ តាមព្រះរាជបំណង !

ក្នុងឧទាហរណ៏នេះ បញ្ជាក់បង្ហាញថា **ទឹក** ជា **គតិ** ; **ពួកសេនា** ជា **តាបស** ; **ភក់** ជា **តណ្ហា** ; **ថ្ម សំរាប់តម្រង់ទឹកឲថ្លាវិញ** ជា **សច្ចភាព** ហើយ សច្ចភាព នេះឯង ដែលជាអ្នក រំលាយឧបសគ្គនាំឲ គតិ មានសម្រិតចិត្ត និង បរិសុទ្ធ។

**ហេតុអ្វីបានជា សច្ចះភាព មាន សន្ទុះចិត្ត ជា ចរិតលក្ខណៈ ?**

តាបស (ពួកសេនា) ស្រមើយើញ គតិផ្សេងច្រើនទៀត នាំឲគាត់ រំដោះ សន្ទុះចិត្ត ពីគំនិត ឲក្លាយជា ភារៈនៃកម្លាំងចិត្ត ដើម្បីរំលាយ តណ្ហា (ភក់) តាមការខំប្រឹងពិសេសមួយ ដើម្បីចង់បាននូវសេចក្តី ប្រាថ្នាមួយ ដែលវា មិនដែលកើតមានបាន និង សមិទ្ធិអ្វីមួយ ដែលវាមិនអាចសម្រេចកើតបាន។ ការប្រឹងពិសេសនេះឯង ជា សន្ទុះចិត្ត ជា ចរិតលក្ខណៈ នៃ សច្ចភាព។

---

[1] Milinda-Panha – Les questions de Milinda –Edition Gallimard.
[2] សច្ចភាព=ប្រើក្នុងន័យ ជំនឿ។
[3] សម្រិតចិត្ត= សុទ្ធកម្ម (La purification)។
[4] សមិតរទេះ=រទេះសង្គ្រាម (Char de guerre)។

ឧបមា មាន ភ្លៀងធំមួយ ធ្លាក់លើភ្នំ បង្កើតបានជា **ជលវេគ**[5] ហូរខ្លាំងធ្លាក់ពីលើភ្នំ នាំឲលិច ដីស្រែចំការ នាំឲស្ទឹងឡើងទឹកខ្លាំង ហៀរច្រាំង ហើយមានមនុស្សកុះករ នាំគ្នាមកមើល ទឹកឡើងនេះ តែមិនដឹងថា វាមានជម្រៅត្រឹមប៉ុណ្ណា គិតតែនាំគ្នាបារម្ភ ពីវិបាក ពី ទឹកជំនន់។ តែពេលនោះ មានបុគ្គលម្នាក់ ឥតរួញរា ព្រោះមានជំនឿលើកម្លាំងខ្លួន ថាគាត់ អាចធ្វើបាន ដើរចុះទឹក ឆ្លងស្ទឹងដែលនាំឲគាត់ដឹងពិត ពីជម្រៅទឹកលិច។ ឃើញដូច្នេះ មនុស្សទាំងឡាយ ក៏នាំគ្នា យកតម្រាប់ តាមបុគ្គលនេះ។ ទង្វើនេះ នាំឲពួកគាត់ លែងមានបារម្ភក្នុងចិត្ត ព្រោះដឹងច្បាស់ នូវជម្រៅទឹកជំនន់។ ស្ថានការណ៍នេះ ក៏ដូចគ្នានឹង តាបស (ពួកសេនា) ស្រមើឃើញ គតិផ្សេងច្រើនទៀត នាំឲគាត់ រំដោះ សន្ទុះចិត្ត ពីគំនិត ឲក្លាយជា ភារៈនៃកម្លាំងចិត្ត ដើម្បីរំលាយ តណ្ហា (ភក់) ដែលប្រដូចនឹង ការបារម្ភ នោះឯង។

## ដំបូន្មាន ក្នុងការពិចារណា របស់ ភក្ខុ បញ្ញា

ដំណោះស្រាយ នូវ មហន្តរាយ ដែល ប្រជាជាតិខ្មែរ កំពុងជួបប្រទះ តម្រូវឲ ប្រជាពលរដ្ឋខ្មែរមាន គំនិតថ្មី ដែលនាំបង្កើតជា កម្លាំងចិត្ត ឬ សន្ទុះចិត្ត ដើម្បី យកមកធ្វើជាអាវុធ សំរាប់ វាយ រំលាយ មហន្តរាយ (ភក់) ក្នុងសច្ចភាព (ជំនឿ) ថា ខ្មែរយើងអាច មានអំណាច អាចធ្វើឲ វា សម្រេចបាន។ តែក្នុង បេសកកម្ម ដ៏ពិសេសនេះ ខ្មែរយើង ត្រូវចាំបាច់មាន អ្នកដឹកនាំ មាន សច្ចភាព មានសេចក្តីក្លាហាន មាន គតិ ថ្លាឆ្វង់ បរិសុទ្ធ យកប្រយោជន៏ជាតិ ជា គ្រឹះ នៃ ចលនា រំលាយ មហន្តរាយជាតិ។

ដំបូន្មាន របស់ ភិក្ខុ ពញ្ញា ជា យោង សំរាប់ ខ្មែរម្នាក់ យកទៅពិចារណា ដើម្បីឲ រីកសាយ នូវ បញ្ហាខ្លួនឯង ក្នុង យាត្រានៃការរំដោះជាតិខ្មែរ ដើម្បីសុភមង្គលនៃប្រជាជាតិ។ លុះត្រាតែខ្មែរ យើងមាន សច្ចភាព មិនអាចរួញរាបាន ថាយើងនឹងអាច រំដោះជាតិបាន ពី គ្រប់គ្រោះថ្នាក់ ដែលប្រជាជាតិខ្មែរកំពុងជួបប្រទះ ទើបខ្មែរយើង រំដោះ សន្ទុះចិត្ត នៃ សេចក្តីក្លាហាន ពី គតិ អវិជ្ជមាន ដែលវា ដុះជាស្លែ នៅក្នុង គតិយើង ជាយូរយារមកហើយ។ វាយរំលាយ មហន្តរាយ ដែលមានកើតឡើងនៅស្រុកខ្មែរបច្ចុប្បន្ន ជា វិញ្ញាសាបង្ខំមួយ ដែលខ្មែរយើងត្រូវតែធ្វើឲបាន សម្រេចបាន ជាដាច់ខាត ពុំនោះសោត គឺ ប្រជាជាតិ ច្បាស់ជា វិនាសជាពុំខាន។

ΩΩΩΩΩ

[5] ជលវេគ=ខ្សែទឹកហូរខ្លាំង (Une torrent)។

# ការពិចារណា

Les réflexions

## អ្វីជា ចរិតលក្ខណៈ នៃ ការពិចារណា ?

ជា **ការរាប់ចំនួន** និង **ការទុកជាត្រូវ**។

**ហេតុអ្វីបានជា ការពិចារណា មាន ការរាប់ចំនួន ជា ចរិតលក្ខណៈ ?**

ការពិចារណា រាប់ចំនួន ភារៈនៃ ចិត្តមនុស្ស កើតមានឡើង ដូចយ៉ាង ៖ ចរិតដែលនាំឲសុខ ឬ ចរិតដែលនាំឲទុក ; ចរិកដែលនាំឲបនោ្ទស ឬ ចរិកមិនអាចនិន្ទានបាន ; ចរិកទាបថោក ឬ ចរិកឧត្តុងឧត្តម ; ចរិកខ្មៅ ឬ ចរិកស ហើយចរិកនិមួយៗ វាមាន បែងចែក ជាផ្នែកតូចៗជាច្រើនទៀត។ ក្នុងធម៌ នេះហើយ ជា ចតុគោល នៃ ការពិចារណា សំរាប់ ភាវនា, ចតុគោល សំរាប់ ការប្រឹងប្រែង, ចតុគោល នៃ មូលដ្ឋាន នៃ អំណាចអស្ចារ្យ, ជា ធាតុ ប្រាំពីរ យ៉ាង នៃព្រះធម៌, ជា មាគ៌ាដ៏ថ្លៃថ្លា ហៅថា ផ្លូវផលា ទាំងប្រាំបីយ៉ាង។ ចរិកទាំអស់នេះហើយ ជា សេចក្ដីស្ងប់ចិត្ត, ការឈ្វេងយល់, វិទ្យាសាស្ត្រ និង ការរំលាយទុក្ខ។ ផលដែលកើតមានពី ការពិចារណានេះ គឺ ការស្វែងយល់ នូវ ភារៈ នៃ ចិត្តមនុស្ស ស្រង់យកតែចរិតល្អ ហើយ ជៀសវៀង នូវ ចរិត ដែលជា ប្រភពនៃទុក្ខ ; អនុវត្តន៏ តែអំពើល្អ  ហើយ បោះបង់ នូវ អំពើ ថោកទាប។

ឧបមា មេឃ្លាំងព្រះរាជទ្រព្យ រាប់ចំនួន សម្បត្តិក្សត្រ ទាំងថ្ងៃយប់ ដើម្បីថ្វាយជាដំណឹង ឲបានច្បាស់លាស់ ដល់ព្រះរាជា នូវ សព្វចំនួន រាជភោគទ្រព្យ ដែលមាន ព្រះអង្គជាម្ចាស់ដាច់មុខ។

**ហេតុអ្វីបានជា ការពិចារណា មាន ការទុកជាត្រូវ ជា ចរិតលក្ខណៈ ?**

ការពិចារណា គឺ ជាការពិនិត្រ នៃ ប្រភេទ ចិត្តមនុស្ស ល្អ ឬ អាក្រក់ ហើយ ធ្វើការ វិនិច្ឆ័យថា ល្អ ឬ មិនល្អ, មាន ប្រយោជន៏ ឬ នាំឲអន្តរាយ។ ផលដែលកើតមានពី ការពិចារណានេះ គឺ ការទទួលស្គាល់ អ្វី ដែលទុកជាត្រូវ និង អ្វីដែលទុកជា អន្តរាយ។

ឧបមា ដូច រដ្ឋមន្ត្រីវាំង របស់ ព្រះមហាក្សត្យ ស្គាល់ច្បាស់ នូវ ចរិត ល្អ ឬ មិនល្អ, មានសមត្ថាភាព ឬ គ្មានសមត្ថភាព គ្រប់បុគ្គលិក នៃរាជក្រមការ បំរើព្រះមហាក្សត្យ។

## ដំបូន្មាន ក្នុងការពិចារណា របស់ ភន្ដ បញ្ញា

ដំណោះស្រាយ នូវ មហន្តរាយ ដែល ប្រជាជាតិខ្មែរ កំពុងជួបប្រទះ តម្រូវឲ អ្នកដឹកនាំជាតិមានចរិតលក្ខណៈ ជាអ្នកដឹងច្បាស់ ពី សព្វបញ្ហាជាតិ សព្វគ្រោះថ្នាក់ជាតិ ហើយ ជ្រើសរើស អ្នកដែល

មានចរិតល្អ និង មាន សមត្ថភាព យកមក ធ្វើកិច្ចការរដ្ឋ ដើម្បី បំរើប្រជាជាតិ និង ស្វែងរក សុភមង្គល ដល់ ប្រជាពលរដ្ឋ។ អ្នក ដែលមានចរិតអាក្រក់ និង គ្មាន សមត្ថភាព គឺជា មនុស្ស នាំមក នូវ សេចក្តីអន្តរាយ ដល់ប្រជាជាតិ។

ΩΩΩΩΩ

## ថាមពល

L’énergie

### អ្វីជា ចរិតលក្ខណៈ នៃ ថាមពល ?

ជា **ការឧបត្ថម**

**ហេតុអ្វីបានជា ថាមពល មាន កាឧបត្ថម ជា ចរិតលក្ខណៈ ?**

ចិត្តមនុស្ស មាន ការឧបត្ថម ជា កម្លាំងមួយ ឥតរងាប់បាននោះឡើយ។

ឧបមា មាន ផ្ទះមួយ បាក់បែង ចង់រលំ បើគេយក ឈើមាំតាន់មួយដើម មកកល់វា គឺវាមិន អាចរលំបាននោះឡើយ។

ឧបមា មាន កងទ័ព តូចមួយ វាយដកថយ ពីសមរភូមិ ដោយសាខ្លាំង មានកម្លាំងខ្លាំង វាយ សំរុកមកលើខ្លួន តែបើព្រះរាជា បញ្ជូនកងជំនួយ ទៅជួយ ច្បាស់ជា វាអាចវាយតបតខ្លាំងវិញ បាន ហើយ អាចនឹងនាំឲមានជ័យជំនះទៀតផង។

### ដំបូន្មាន ក្នុងការពិចារណា របស់ ភក្ក បញ្ញា

ដំណោះស្រាយ នូវ មហន្តរាយ ដែល ប្រជាជាតិខ្មែរ កំពុងជួបប្រទះ តម្រូវឲ ប្រជាពលរដ្ឋ ងើប ឡើង ចងបាច់ជា កងជំនួយ ជួយ ឧបត្ថម ប្រជាជាតិ កុំឲបាក់បែក រលំបាន។ ការឧបត្ថម ពី សំណាក់ប្រជាពលរដ្ឋនេះឯង ជា ការសង្គ្រោះជាតិ។

ថ្ងៃទី៣ មករា ឆ្នាំ ២០១៥

ឧប សៅ សង្ហា